# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៣៦ សសរ

## សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការស្វែងយល់ និងវាយតម្លៃលើបាតុភាពមិនប្រក្រតីពាក់ព័ន្ធនឹង សេចក្តីជូនដំណឹងលេខ ៣៤៩ សជណ ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ២០០៥ លេខ ១៣៨២ សជណ.ពប ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៥ និងលេខ ៧៤៥ សជណ ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៥ (ពីរ) របស់ទីស្តីការគណៈរដ្ឋមន្ត្រី

-------

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- តាមសំណូមពរចាំបាច់នៃការងារ

## សម្រេច

**ប្រការ ១ :** ត្រូវបានបង្កើតគណៈកម្មការស្វែងយល់ និងវាយតម្លៃលើបាតុភាពមិនប្រក្រតី ពាក់ព័ន្ធនឹងសេចក្តីជូនដំណឹងលេខ ៣៤៩ សជណ ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០៥ លេខ ១៣៨២ សជណ.ពប ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៥ និងលេខ ៧៤៥ សជណ ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៥ (ពីរ) របស់ទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធាន

២-ឯកឧត្តម ម៉ិន អ៊ីយ រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៣-ឯកឧត្តម កាន់ ម៉ន រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៤-ឯកឧត្តម ត្រាំ សុខា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក

៥-ឯកឧត្តម ខាន់ សារឿន រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក

៦-ឯកឧត្តម **នុត ណារ៉ង** រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក

៧-ឯកឧត្តម នាយឧត្តមសេនីយ៍ **ហុក ឡុងឌី** អគ្គស្នងការ នៃអគ្គស្នងការដ្ឋាន នគរបាលជាតិ ក្រសួងមហាផ្ទៃ សមាជិក

៨-ឯកឧត្តម **ឱម យ៉ិនទៀង** ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី សមាជិក

៩-ឯកឧត្តម **ណាឌី តាន់** អគ្គលេខាធិការរាជរដ្ឋាភិបាល សមាជិក

១០-ឯកឧត្តម **ឡូត លុច** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ សមាជិក

១១- ឯកឧត្តម **កែប ជុតិមា** អភិបាលរាជធានីភ្នំពេញ សមាជិក

១២-ឯកឧត្តម **ស្វាយ ស៊ីថា** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

១៣-ឯកឧត្តម **ហេង ពៅ** ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី និងជាស្នងការ អគ្គស្នងការ ដ្ឋាននគរបាលរាជធានីភ្នំពេញ សមាជិក

១៤-ឯកឧត្តម **ស៊ាន ទិសុន្ទ** ប្រធានស្តីទី អង្គភាពប្រឆាំងរាល់សកម្មភាព អំពើពុករលួយ សមាជិក

**ប្រការ ២ :** គណៈកម្មការនេះមានភារកិច្ចស្រាវជ្រាវស្វែងយល់ និងវាយតម្លៃលើបាតុភាពមិនប្រក្រតី ពាក់ព័ន្ធនឹងសេចក្តីជូនដំណឹងលេខ ៣៤៩ សជណ ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០៥ លេខ ១៣៨២ សជណ.ពប ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៥ និងលេខ ៧៤៥ សជណ ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៥ (ពីរ) របស់ទីស្តីការគណៈរដ្ឋមន្ត្រី ឱ្យបានត្រឹមត្រូវគ្រប់ជ្រុងជ្រោយ រួចលើកយោបល់ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច ។

**ប្រការ ៣ :** សមាជិករបស់គណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៤ :** ប្រធានគណៈកម្មការនេះមានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័នដែលមានការពាក់ព័ន្ធ ដើម្បីចូលរួមបំភ្លឺ តាមការចាំបាច់ ។

**ប្រការ ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលរាជធានីភ្នំពេញ ព្រមទាំងសាមីខ្លួន ដែលមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៥

**ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយកនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- ឯកសារ កាលប្បវត្តិ